

# ឱកាសកម្មសិក្សា

## ស្ម័គ្រចិត្តពីអង្គការហ្វ្រេនឡ

friends international

តើអ្នកជិតបញ្ចប់ការសិក្សា ឬ ទើបនឹងបញ្ចប់ការសិក្សាថ្មីៗមែនទេ ?
តើអ្នកចាប់អារម្មណ៍ ហើយចង់ចាប់ផ្ដើមការងារដំបូងរបស់អ្នកជាមួយអង្គការប្រកបដោយភាពច្នៃប្រឌិតក្នុងការធ្វើការជាមួយកុមារនិងយុវជនដែរឬទេ ?
បើអ្នកឆ្លើយថា “yes!” អ្នកអាចនឹងក្លាយជាមនុស្សម្នាក់ដែលយើងកំពុងតែស្វែងរក !

**តើជំនាញទាំងនេះ ម៉េចដែរ ? តើអ្នកចាប់អារម្មណ៍ទៅលើមួយណាដែរ ?**

**ការងារផ្នែកសង្គម** –ជួយការងារស្ទួលហើយអាចរៀនបន្ថែមពីក្រុមការងារដែលមានបទពិសោធន៍យូរឆ្នាំ និងធ្វើការដោយផ្ទាល់ជាមួយអ្នកទទួលផលដែលអាចអ្នកអាចយល់បានច្បាស់អំពីទិដ្ឋភាពពិតនៃសង្គម

**ផ្នែកទីផ្សារ** – ធ្វើការវិភាគលើទីផ្សារគោលដៅ និង បង្កើនការលក់ក្នុងមណ្ឌលអាជីវកម្ម ដូចជា Friends n Stuff និងភោជនីយដ្ឋាន Friends

**ផ្នែកទំនាក់ទំនង** – ប្រើទេពកោសល្យរបស់អ្នក ដើម្បីផ្សព្វផ្សាយអំពីអ្វីដែលយើងបានធ្វើ ជាពិសេសយុទ្ធនាការទៅលើ ការរក្សាគ្រួសារឲ្យរស់នៅជាមួយគ្នា ( Keeping Families Together )

**ផ្នែកធនធានមនុស្ស/រដ្ឋបាល** – ជួយគាំទ្រដល់ក្រុមការងារ និងប្រព័ន្ធគ្រប់គ្រងជំនាញនិងការអភិវឌ្ឍន៍, ជួយរៀបចំកសាងការងារជាក្រុម, រៀនអំពីដំណើរការ ការងាររដ្ឋបាល

**ផ្នែកហិរញ្ញវត្ថុ** – បង្កើន និងពង្រឹងសមាសភាព នៃរបៀបចាយលុយ ឱ្យមានតម្លាភាព និងនិរន្តរភាព

**គ្រូបង្រៀន** – យកឱកាសនេះដើម្បីបង្កើតអីថ្មីនិងផ្ទេរចំណេះដឹងរបស់អ្នកទៅអោយកុមារនៅក្នុងមណ្ឌល ឬនៅក្នុងសហគមន៍

**បច្ចេកវិទ្យាព័ត៌មាន** – ធ្វើការជាមួយអ្នកជំនាញបច្ចេកវិទ្យាព័ត៌មានរបស់យើងដើម្បីឲ្យប្រាកដថាក្រុមការងាររបស់យើងមានគន្លឹះការងារត្រឹមត្រូវដើម្បីបំពេញការងារ

**ផ្នែករចនា** – ជួយដល់ក្រុមការងារជាមួយនឹងជំនាញរចនារូបភាពរបស់អ្នក និងបង្ហាញពីគំនិតច្នៃប្រឌិតរបស់អ្នកដោយការបង្កើតសំភារៈការផ្សព្វផ្សាយនិងផលិតផលថ្មីៗ

**Friends Futures Factory events** – ចូលរួមលើកកំពស់យ៉ាងសកម្មចំពោះកន្លែងថ្មីរបស់យើង( FFF ) និងធ្វើការរៀបចំព្រឹត្តិការណ៍គួរអោយចាប់អារម្មណ៍ផ្សេងៗដូចជាកម្មវិធីបុណ្យជាតិ ការតាំងពិពណ៌ និងការប្រគុំតន្ត្រីជាដើម។

យើងចង់ផ្ដល់ឱកាសអោយយុវវ័យក្នុងការចាប់ផ្ដើមអាជីពនិងអភិវឌ្ឍន៍សក្ដានុពល ដោយការធ្វើការងារជាក្រុមជាមួយគ្រប់ជាតិសាសន៍និងគ្រប់ជំនាញនៅក្នុងអង្គការយើងនៅក្នុងទីក្រុងភ្នំពេញ។ កម្មវិធីកម្មសិក្សានេះអនុញ្ញាតិអោយអ្នកជ្រើសយកផ្នែកណាមួយដែលបានរៀបរាប់ខាងលើមកអនុវត្តន៍ និងទទួលបទពិសោធន៍ពិតសំរាប់ជីវិត។ អ្នកនឹងចូលរួមជាមួយគម្រោងផ្សេងៗរបស់យើងដូចជា ការការពារកុមារ សេវាសង្គម ការអប់រំ សុខភាព ផ្នែករកការងារអោយធ្វើ និងវគ្គបណ្ដុះបណ្ដាល។ អ្នកអាចចាប់យកឱកាសនេះក្នុងការធ្វើការផ្ទាល់ជាមួយអ្នកទទួលផលរបស់យើងនៅក្នុងសហគមន៍ ក៏ដូចជាអ្នកអាជីវកម្មផ្សេង អតិថិជន រដ្ឋាភិបាល ម្ចាស់ជំនួយ និងអង្គការដៃគូ អ្នកទេសចរណ៍ និងដៃគូផ្សេងៗទៀត។ យើងមានគ្រូបង្គោលតាមជំនាញដើម្បីបង្ហាញអ្នកគ្រប់លទ្ធភាពទាំងអស់ដែលត្រូវរៀននិងអភិវឌ្ឍន៍ខ្លួនអ្នក។

**តើអ្វីដែលអ្នកនឹងទទួលបាននៅពេលចុះកម្មសិក្សាជាមួយអង្គការ ហ្វ្រេនឡ ?**

- រៀនពីរបៀបដឹកនាំរបស់អង្គការ/ការងារសង្គម ( មានបទពិសោធន៍២៥ឆ្នាំ និងមានវត្តមាននៅប្រទេសកម្ពុជា ថៃ ឡាវ ឥណ្ឌូនេស៊ី និងប្រទេសស្វីស )
- ទទួលបានបទពិសោធន៍ការងារ និងរៀនពីក្រុមការងារដែលមកពីគ្រប់ជាតិសាសន៍( អង្គការហ្វ្រេនឡមានក្រុមការងារមកពីជាង១៥ប្រទេសផ្សេងគ្នា )
- ធ្វើការនិងរៀនពីក្រុមអ្នកជំនាញទាក់ទងនឹងការងារសង្គម, ការគ្រប់គ្រងគម្រោង, ហិរញ្ញវត្ថុ, ទំនាក់ទំនង, ធនធានមនុស្ស និងការងារតាមជំនាញផ្សេងៗទៀត
- ទទួលបានវគ្គបណ្ដុះបណ្ដាលជំនាញទន់( Soft Skills ) ក្រោមប្រធានបទការងារជាក្រុម, ទំនាក់ទំនង, ការគិតបែបច្នៃប្រឌិត ដែលធ្វើឡើងដោយក្រុមអ្នកជំនាញផ្នែកការងាររបស់យើង
- អ្នកនឹងទទួលបានការណែនាំដោយផ្ទាល់ពីគ្រូបង្គោលម្នាក់ ដែលណែនាំអ្នកអោយទទួលលទ្ធផលល្អបំផុតក្នុងអំឡុងពេលកម្មសិក្សារបស់អ្នក
- អ្នកនឹងមិននៅម្នាក់ឯងទេ ! យើងនឹងចងក្រងជាក្រុមសំរាប់កម្មសិក្សាដើម្បីផ្លាស់ប្ដូរបទពិសោធន៍និងរៀនពីគ្នាទៅវិញទៅមកទទួលបានលិខិតបញ្ជាក់នៅពេលបញ្ចប់កម្មសិក្សា

រយះពេល៖ តិចបំផុតគឺ៣ខែ ទាំងអ្នកចុះកម្មសិក្សាពេញម៉ោង ឬក្រៅម៉ោង ( part-time )

គួរអោយចាប់អារម្មណ៍ដែរទេ? ពិតជាឱកាសពិសេសមែន! ផ្ញើប្រវត្តរូបអ្នក ដោយបញ្ជាក់ពីជំនាញដែលអ្នកចាប់អារម្មណ៍មកកាន់ hr@friends-international.org

Friends team

friends international

Together, building futures.